# សេរីហ្វួរីយេ

(Séries de Fourier)

រៀបរៀងដោយ អាន តៃ្យ គីម អតីតសាស្ត្រាចារ្យទុតិយភូមិ
វាយបញ្ចូលក្នុងកុំព្យូទ័រដោយលោកស្រី ហាង់ ឆវីវ័ណ្ណ

អត្ថបទនេះអាចយកទៅផ្សាយ ជាធម្មទានបាន - ខ្ញុំ អាន តៃ្យគីម (anntaykim@yahoo.fr)។

## អារម្ភកថា

*អត្ថបទនេះកើតឡើង ក្នុងបំណង ឲ្យមានឯកសារផ្សេងៗ ជាភាសាខ្មែរ ឲ្យបានច្រើន ខាងវិទ្យាសាស្ត្រ ដូចជាខាងគណិតសាស្ត្រជាដើម សម្រាប់ជាជំនួយដល់និស្សិតដែលសិក្សាអំពីមុខវិជ្ជាទាំងនោះ ។ ដើមឡើយ នៅឆ្នាំ ២០០៤ ខ្ញុំសរសេរអត្ថបទនេះ សម្រាប់យកទៅបង្រៀនលោកគ្រូអ្នកគ្រូ បង្ហាត់នៅមជ្ឈមណ្ឌល* **ក្រមង៉ុយ** *ក្រុងភ្នំពេញ តែដោយឱកាសពុំអនុញ្ញាត ការបង្រៀននោះក៏អាក់ខានទៅ វិញ។ ទើបតែពេលនេះ ជាឱកាសល្អ ខ្ញុំមានសេចក្តីរីករាយ យកអត្ថបទនេះ មកផ្សាយជាលើកដំបូង ដោយមានលោកស្រី ហាង់ ឆវីវ័ណ្ណ ជួយវាយបញ្ចូលក្នុងកុំព្យូទ័រ។ ដោយពាក្យខ្លះ នៅពេលដែលខ្ញុំសរសេរនោះពុំទាន់មានប្រែជាភាសាខ្មែរ ខ្ញុំក៏ទុកពាក្យនោះជាភាសាបារាំងសិន ។ បើលោកអ្នកអានចេះតែភាសា អង់គ្លេស នោះសូមមើលវចនានុក្រម* **បារាំង-អង់គ្លេស** *សិនទៅ ដើម្បីជាជំនួយដល់ការពន្យល់ ។ សូមអរគុណ ។*

*ខ្ញុំសង្ឃឹមថាអត្ថបទដូចតទៅនេះ អាចផ្តល់ប្រយោជន៍ខ្លះ ជូនលោកអ្នកអានជាមិនខាន ។*
*សង់សៀម៉ាណ ថ្ងៃ ១៩ ឧសភា ឆ្នាំ ២០១៣*
អាន តៃ្យ គីម